ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តត្បូងឃ្មុំ

តុលាការរដ្ឋប្បវេណី
សំណុំរឿងរដ្ឋប្បវេណីលេខ៖ ៥៣
ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២
សាលក្រម
លេខ ៨៩ "ង"
ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២

**<u>សាលក្រម</u>**
**គាំទនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តត្បូងឃ្មុំ**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២

**<u>ចៅក្រម</u>**
**លោក [redacted] ចៅក្រមសាលាដំបូងខេត្តត្បូងឃ្មុំ**
**<u>ក្រឡាបញ្ជី</u>**
**លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តត្បូងឃ្មុំ**

**<u>ដើមចោទ</u>**៖ឈ្មោះ [redacted] **ជាទីន** ភេទស្រី អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ លក់ដូរ ឪពុកឈ្មោះ [redacted] ឡាយ (រស់) ម្តាយឈ្មោះ [redacted] ធារី (រស់) អាសយដ្ឋានបច្ចុប្បន្ននៅ [redacted] ។

-<u>មានអ្នកតំណាងដោយអាណត្តិ</u> ៖ លោកមេធាវី [redacted] អាសយដ្ឋាន អគារលេខ [redacted]

**<u>ចុងចម្លើយ</u>**៖ ឈ្មោះ [redacted] **សុខណោង** ភេទប្រុស អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ លក់ដូរ ឪពុកឈ្មោះ [redacted] គួង (រស់) ម្តាយឈ្មោះ [redacted] ស៊ីណាត (រស់) អាសយដ្ឋានបច្ចុប្បន្ន [redacted]

-<u>អ្នកតំណាងដោយអាណត្តិ</u>៖ "គ្មាន" ។

**I. <u>ខ្លឹមសារនៃសាលក្រម ដែលដើមចោទ ទាមទារឲ្យតុលាការចេញ៖</u>**

១- លែងលះពីចុងចម្លើយ ឈ្មោះ [redacted] សុខណោង ។

២-សុំសិទ្ធិគ្រប់គ្រង និងធ្វើជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] ដេវីត ថ្ងៃខែឆ្នាំកំណើត ១៩-០៦-២០១៩ មានសំបុត្របញ្ជាក់កំណើតលេខ ១៣៨ សៀវភៅកំណើតលេខ ០២/១៩ ចុះថ្ងៃទី២៨-០៦-២០១៩ ។

៣-ធ្វើការបែងចែកទ្រព្យរួមជាពីរចំណែកស្មើគ្នា ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**II. <u>អង្គហេតុ និងចំណុចវិវាទ</u>**

**១-ការសង្ខេបនៃរឿងក្តី**

ក្នុងរឿងក្តីនេះ ដើមចោទអះអាងថា៖ ខ្លួន និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្តីប្រពន្ធ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ: ០៤ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ:០១/១៨ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ នៅសាលាឃុំមេមត់ ស្រុកមេមត់ ខេត្តមេមត់ ។ ក្នុងអំឡុងពេលរួមរស់ជាមួយគ្នា ខ្លួន និងចុងចម្លើយ បានបង្កើតបានកូនចំនួន ០១នាក់ ឈ្មោះ [redacted] ដេវីត ភេទប្រុស កើតថ្ងៃទ១៩ ខែមិថុនា ឆ្នាំ២០១៩ ។ ដោយសារតែការរស់នៅជាមួយគ្នាជាប្តីប្រពន្ធ តែងតែមានភាពរកាំរកូសជាហូរហែ ឈ្លោះប្រកែកគ្នា និងរស់នៅជាមួយគ្នាពុំមានក្តីសុខ ដែលធ្វើឲ្យខ្លួនអស់មនោសញ្ចេតនា ក្នុងការរួមរស់នៅជាមួយចុងចម្លើយតទៅទៀត ទើបខ្លួនទាមទារ



Scanned with CamScanner

លែងលះពីចុងចម្លើយ ។ ដូច្នេះ មានមូលហេតុនៃការលែងលះគ្នា ដូចមានចែងក្នុងចំណុច ង កថាខណ្ឌទី១ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ។ ហើយក្រៅពីធ្វើការទាមទារអំពីការលែងលះទៅកាន់ចុងចម្លើយរួចហើយ ដើមចោទក៏បានទាមទារនូវការកំណត់ថា ខ្លួនគឺជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] ដេវីត និងសុំបែងចែកទ្រព្យរួមជាពីរចំណែកស្មើគ្នា ។

**២-អង្គហេតុដែលជាមូលដ្ឋានដើម្បីពិចារណាអំពីចំណុចវិវាទ៖**

២.១-ដើមចោទ និងចុងចម្លើយ បានទៅចុះបញ្ជីអាពាហ៍ពិពាហ៍ នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ ។ ហើយដោយសារការរស់មានភាពមិនចុះសម្រុងនឹងគ្នា និងមិនមានក្ដីសុខ ដើមចោទក៏ដាក់ពាក្យបណ្ដឹងសុំលែងលះនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ ។ (ភស្តុតាងមាន៖ សំបុត្រអាពាហ៍ពិពាហ៍លេខៈ០៤ នៃសៀវភៅអាពាហ៍ពិពាហ៍លេខៈ០១/១៨ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ និងសេចក្ដីបញ្ជាក់ក្នុងពាក្យបណ្ដឹងចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២) ។

២.២-ស្ថិតក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ដើមចោទ និងចុងចម្លើយបង្កើតបាន០១នាក់ ឈ្មោះ [redacted] ដេវីត ភេទប្រុស កើតថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ (ភស្តុតាងមាន៖ សំបុត្រកំណើតលេខៈ១៣៨ នៃសៀវភៅកំណើតលេខៈ០៤/១៩ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ចេញសាលាឃុំមេមត់) ។

២.៣-នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី១ ដែលត្រូវបានធ្វើឡើងនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ និងនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២ ដែលត្រូវបានធ្វើឡើងនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២៖

-មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ បានថ្លែងការណ៍ថា៖ ភាគីទាំងសងខាងបានព្រមព្រៀងគ្នាក្នុងការលែងលះ ប៉ុន្តែបញ្ហាដែលត្រូវលើកឡើងគឺ អំណាមេបាលើកូន និងទ្រព្យរួម ។ ដោយសារតែកូននៅតូច ហើយមានជម្ងឺ ប្រហែលជាជម្ងឺអូទីស្សឹម ម៉្យាងវិញទៀតកូនតែងតែនៅជាមួយម្ដាយ ដូចនេះសូមឲ្យកូននៅជាមួយកូនក្ដីរបស់ខ្លួនដែលជាដើមចោទ។

-ចុងចម្លើយ៖ បានអះអាងថា ចំពោះការលែងលះ ខ្លួនមិនមានការជំទាស់ទេ ហើយចំពោះអំណាចមេបាលើកូន គឺខ្លួនឲ្យសិទ្ធិចិញ្ចឹមកូន គឺខ្លួនឲ្យដើមចោទអ្នកចិញ្ចឹមបីបាច់ថែរក្សាកូន ដោយខ្លួនសុំសិទ្ធិសួរសុខទុក្ខកូន និងយកកូនទៅលេងផ្ទះរៀងរាល់ចុងសប្ដាហ៍ ពោលគឺយកកូនទៅលេងនៅថ្ងៃសៅរ៍ ដោយយកមកគេងមួយយប់ ហើយថ្ងៃអាទិត្យយកទៅឲ្យដើមចោទវិញ និងសុំយកកូនទៅលេងក្នុងពេលមានកម្មវិធីបុណ្យទានប្រពៃណី និងបុណ្យទានដែលកើតឡើងជាយថាហេតុចូលរួមបានតាមជាក់ស្ដែង ។ លើសពីនេះទៀត ចុងចម្លើយស្នើសុំឲ្យដើមចោទផ្ដល់ដំណឹង និងពិភាក្សាជាមួយខ្លួនជាឪពុកអំពីស្ថានភាពរស់នៅរបស់កូនដូចជា ការសិក្សា ផ្លាស់ទីលំនៅ សុខភាព ជាដើម ហើយស្នើសុំរក្សាការប្រើនាមត្រកូលរបស់កូន (អ៊ឹង) នៅដដែល ដោយមិនមានការផ្លាស់ប្ដូរ ។

-ដើមចោទ៖ ចំពោះដីមានទំហំ ១.៥២៧ ម៉ែត្រការ៉េ នៅសង្កមមានជ័យចាស់ ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងផ្ទះវីឡាកូនកាត់ (បង់រំលស់) ផ្ទះលេខ ៣០ ផ្លូវP៤៦ គំរោងផាកលេន លេខ ៥៩៨ មានទីតាំងស្ថិតនៅសង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ គឺជាទ្រព្យរួម និងសុំបែងចែកទ្រព្យជាពីរចំណែកស្មើគ្នា ។

ចំពោះផ្ទះវីឡាកូនកាត់ដែលកំពុងបង់រំលស់ខាងលើ គឺកូនក្ដីខ្លួនស្នើសុំឲ្យចុងចម្លើយ ជួយចូលរួមបង់រំលស់រួមគ្នាបន្ត ពីព្រោះចុងចម្លើយអាក់ខានបង់ចំនួនបីខែមកហើយ និងសុំឲ្យចុងចម្លើយពិចារណាតម្លៃ ហើយទិញយកពីកូនក្ដីខ្លួន ឬក៏លក់ឲ្យកូនក្ដីរបស់ខ្លួន ឬលក់ឲ្យខាងទីផ្សារ ដោយកំណត់តម្លៃឲ្យបានច្បាស់លាស់ ។

និងសុំទាមទារឲ្យចុងចម្លើយប្រគល់ប្រាក់ចំនួន ១៧.០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ដែលចុងចម្លើយបានយកទៅទិញរថយន្ត មកឲ្យកូនក្ដីខ្លួនវិញ ពីព្រោះប្រាក់នេះ ជាទ្រព្យដោយឡែករបស់កូនក្ដីខ្លួន ។

-ចុងចម្លើយ៖ ចំពោះដីទំហំ ១.៥២៧ ម៉ែត្រការ៉េ នៅសង្កមមានជ័យចាស់ ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ជាទ្រព្យរួមបំណុល ដោយសារតែខ្លួនខ្ចីប្រាក់ពីបងប្រុសរបស់ខ្លួនទៅទិញដីនោះ ដូចនេះខ្លួនសូមឲ្យដើមចោទ



Scanned with CamScanner

ជួយដោះបំណុលដែលខ្លួនខ្ចីពីបងប្រុសរបស់ខ្លួនជាមុនសិន ហើយប្រសិនបើដើមចោទចង់ចែកដីនោះជាពីរចំណែកស្មើគ្នា លុះត្រាតែជួយសងបំណុលឲ្យដាច់សិន ទើបខ្លួនសុខចិត្តបែងចែកជាពីរចំណែក ។ ក្នុងរឿងនេះ ដើមចោទក៏បានដឹងលឺថាខ្លួនខ្ចីលុយពីបងប្រុសរបស់ខ្លួនដែរ ។

ចំណែកឯផ្ទះវីឡាកូនកាត់នៅជីពម៉ុងដែលកំពុងបង់រំលស់វិញ គឺខ្លួនពុំមានលទ្ធភាពបង់បន្តទេ ដូចនេះសូមឲ្យដើមចោទកាត់យក និងដាក់លក់ទៅតាមទីផ្សារ ហើយចែកជាពីរចំណែកស្មើគ្នា ។

ចំពោះប្រាក់ចំនួន ១៧.០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិកដែលដើមចោទលើកឡើង គឺជាទ្រព្យរួមពីព្រោះជាប្រាក់ដែលរកបានក្នុងចំណងអាពាហ៍ពិពាហ៍ ។

លើលពីនេះទៅទៀត ខ្លួនសូមទាមទារយកគ្រឿងអលង្ការចំនួន ៣ឈុត ពីដើមចោទមកវិញរួមមាន កងដៃ ខ្សែក និងក្រវិល សរុបជាប្រាក់ប្រហែលចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក ដែលបានទិញនាឱកាសថ្ងៃខួបកំណើតរបស់ដើមចោទ និងនៅក្នុងកម្មវិធីផ្សេងៗ ដែលជាប្រាក់ផ្ទាល់ខ្លួនដែលខ្លួនខំរកក្នុងចំណងអាពាហ៍ពិពាហ៍ ។

-មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ បានថ្លែងការណ៍តបថា៖ អ្វីដែលចុងចម្លើយបានស្នើសុំចំពោះកូនមួយចំនួននោះ គឺអាចនាំឲ្យមានបញ្ហាជាច្រើន ពីព្រោះក្មេងទើបតែមានអាយុ ៣ឆ្នាំ ហើយសុខភាពរបស់ក្មេងមិនមានសុខភាពល្អដូចក្មេងធម្មតានោះទេ ហើយសព្វថ្ងៃកំពុងសង្ស័យថាមានជម្ងឺអូទីស្សឹម ហើយពេទ្យខាងចិត្តសាស្ត្រកំពុងតាមដានអំពីជម្ងឺនេះ ដូចនេះការស្នើសុំច្រើនចំណុចរបស់ចុងចម្លើយ ធ្វើឲ្យកូនក្តីខ្លួនមានការព្រួយបារម្ភពីព្រោះខ្លាចប៉ះពាល់ដល់បញ្ហាខាងលើ ហេតុនេះខ្លួនសុំឲ្យចុងចម្លើយមកលេងកូនវិញ មិនគួរគប្បីឲ្យចុងចម្លើយយកកូនទៅលេងនោះទេ ។

ចំពោះផ្ទះវីឡាកូនកាត់ដែលបង់រំលស់ គឺសូមអោយចុងចម្លើយដាក់តម្លៃ ដើម្បីកូនក្តីខ្លួនយកទៅពិចារណា ហើយសូមឲ្យចុងចម្លើយប្រឹងប្រែងក្នុងការជួយបង់រំលស់ និងសូមឲ្យចុងចម្លើយកំណត់ពេលក្នុងការលក់ រួមទាំងតម្លៃលក់ឲ្យបានច្បាស់លាស់។

គ្រឿងអលង្ការដែលចុងចម្លើយបានលើកឡើង គឺអំណោយដែលចុងចម្លើយបានទិញឲ្យកូនក្តីខ្លួនក្នុងឱកាសថ្ងៃខួបកំណើត និងកម្មវិធីផ្សេងៗ ចំពោះពាក្យថា អំណោយ គឺកូនក្តីខ្លួនមិនមានកាតព្វកិច្ចនឹងសងត្រឡប់ទៅវិញនោះទេ ។

**៣-ចំណុចវិវាទ និងការអះអាងរបស់ភាគីចំពោះចំណុចវិវាទ៖**

ក្នុងរឿងក្តីនេះ ដើមចោទ និងចុងចម្លើយ មិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ទេ ហើយទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយត្រូវបានបែកបាក់ គ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានទេ ។ ដូច្នេះហើយ ដោយសារតែតុលាការទទួលស្គាល់អំពីមូលហេតុនៃការលែងលះគ្នា ដែលមានចែងនៅក្នុងចំណុច ង កថាខណ្ឌទី១ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ។ ដូចនេះ បណ្តឹងទាមទារលែងលះរបស់ដើមចោទ គឺមានមូលហេតុ ។

ចំពោះអ្នកមានសិទ្ធិអំណាចមេបាក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន គឺចុងចម្លើយឯកភាពក្នុងការប្រគល់សិទ្ធិឲ្យដើមចោទជាអ្នកមានសិទ្ធិអំណាចមេបាលើកូនស្របតាមការទាមទារ ។ ដូច្នេះ តុលាការនឹងទទួលស្គាល់ចំពោះការសម្រេចអំពីអ្នកដែលមានអំណាចមេបា ដែលមានចែងនៅក្នុង កថាខណ្ឌទី១ មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី។

តាមរយៈអង្គហេតុដែលជាមូលដ្ឋានសម្រាប់ពិចារណាលើចំណុចវិវាទ តុលាការអាចកំណត់បាននូវចំណុចវិវាទដូចខាងក្រោម៖

៣.១-ការកំណត់អំពីរបៀបចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន៖

- **ការអះអាងរបស់ចុងចម្លើយ៖** ខ្លួនសុំសិទ្ធិក្នុងការយកកូនទៅលេងជារៀងរាល់ចុងសប្តាហ៍ ពោលគឺយកកូនទៅលេងនៅថ្ងៃសៅរ៍ ដោយយកមកសម្រាកមួយយប់ ហើយថ្ងៃអាទិត្យយកទៅឲ្យដើមចោទវិញ និងសុំយកកូនទៅលេងក្នុងពេលមានកម្មវិធីបុណ្យទានប្រពៃណី និងបុណ្យទានដែលកើតឡើងជាយថាហេតុ ចូលរួមបានតាមជាក់ស្តែង ។ លើសពីនេះទៀត ខ្លួនស្នើសុំឲ្យដើមចោទផ្តល់ដំណឹង និងពិភាក្សាជាមួយខ្លួនជាឪពុកអំពីស្ថាន



Scanned with CamScanner

ភាពរស់នៅរបស់កូនដូចជា ការសិក្សា ផ្លាស់ទីលំនៅ សុខភាព ជាដើម។ ម៉្យាងវិញទៀតចុងចម្លើយស្នើសុំរក្សាការប្រើនាមត្រកូលរបស់កូន ([redacted]) នៅដដែល។

កូននេះ ខ្លួនជាអ្នកមើលថែកូនតាំងពីកើតរហូតដល់មានរឿងកើតឡើង ហេតុដូច្នេះខ្លួនដឹងពីការថែទាំកូន ។ ជារៀងរាល់ថ្ងៃ ខ្លួនជាអ្នកមើលថែរក្សាកូន បង្រៀន បំបៅទឹកដោះគោកូន ហើយពេលដែលកូនឈឺតាំងពីកើតមករហូតដល់មានរឿងកើតឡើងក្នុងគ្រួសារ គឺខ្លួនតែងតែនៅក្បែរកូនគ្រប់ពេល និងយកកូនទៅព្យាបាលនៅពេទ្យភ្នំពេញ ហើយចំពោះការចំណាយលើការព្យាបាលកូន សម្ភារៈប្រើប្រាស់របស់កូន ទឹកដោះគោកូនរាល់ខែ គឺខ្លួនរ៉ាប់រង និងចំណាយស្ទើរទាំងស្រុង។ ចំណែកឯ បញ្ហាដែលលើកឡើងថាកូនរបស់ខ្លួនមានជម្ងឺ និងសង្ស័យថាកើតជម្ងឺអូទីស្សឹម ខ្លួនសូមបញ្ជាក់ថា អូទីស្សឹម មិនមែនជាជម្ងឺដែលត្រូវការគ្រូពេទ្យ និងថ្នាំព្យាបាលនោះទេ សូម្បីតែសហរដ្ឋអាមេរិកដែលជាប្រទេសជឿនលឿន ក៏អះអាងបែបនេះដែរ ។ អូទីស្សឹម នៅមិនទាន់មានប្រទេសណាមួយហ៊ានអះអាងថាកើតមកពីបញ្ហាអ្វីឡើយ គ្រាន់តែការសន្និដ្ឋានគឺសង្ស័យថាមកពី វិទ្យុសកម្ម ដោយសារការឲ្យកូនមើលគ្រឿងអេឡិចត្រូនិចច្រើន ដូចជា ទូរទស្សន៍ ទូរស័ព្ទ អាយផេត តែម្នាក់ឯង ការទុកឲ្យកូននៅលេងតែម្នាក់ឯង និងការមិនឲ្យកូនទៅប្រាស្រ័យទាក់ទងជាមួយក្មេងៗដទៃ និងកត្តាហ្សែនពីកំណើត ។ ហេតុនេះប្រសិនបើសង្ស័យថាកូនមានជម្ងឺអូទីស្សឹម គឺត្រូវយកកូនមកលេងប្រាស្រ័យទាក់ទងជាមួយក្មេងដទៃទៀត ក៏ដូចជាយកកូនទៅសាលារៀន បង្ហាត់បង្រៀនកូន ពីរបៀបរស់នៅប្រចាំថ្ងៃ និងពិសេសជាងនេះទៅទៀត គឺត្រូវមានការចូលរួមមើលថែទាំពីឪពុកម្តាយជាចាំបាច់បំផុត។ ហេតុដូចនេះហើយ ការអះអាងរបស់មេធាវីខាងដើមចោទ គឺជាលេស ដែលមិនចង់ឲ្យខ្លួនជួបមើលថែរក្សាបីបាច់កូនទាល់តែសោះ និង មានចេតនាចង់កាត់ផ្តាច់ទំនាក់ទំនងរវាងខ្លួន និងកូន ។

**-ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ៖** ប្រសិនបើសម្រេចតាមការស្នើសុំរបស់ចុងចម្លើយ ដែលទាមទារយកកូនទៅលេងនៅថ្ងៃសៅរ៍ អាទិត្យជារៀងរាល់សប្តាហ៍ និងនៅពេលមានបុណ្យជាតិ កូនក្តីខ្លួនមិនឯកភាពទេ ពីព្រោះអាចនាំឲ្យមានផលប៉ះពាល់ដល់កូនរបស់កូនក្តីខ្លួន ដោយសារតែក្មេងទើបតែមានអាយុ ៣ឆ្នាំ ខ្លាចមានការថែទាំខុសគ្នា។ ម៉្យាងវិញទៀត កូនរបស់កូនក្តីរបស់ខ្លួនកំពុងតែសិក្សា ចំណែកឯខាងក្រុមគ្រូពេទ្យជំនាញកំពុងតែពិនិត្យ ហើយសង្ស័យថាកូនរបស់កូនក្តីរបស់ខ្លួនអាចនឹងកើតជម្ងឺអូទីស្សឹម ដែលចាំបាច់ត្រូវមានការមើលថែទាំជាប្រចាំ និងដោយយកចិត្តទុកដាក់បំផុតពីម្តាយដែលជាកូនក្តីរបស់ខ្លួន។ ហេតុដូចនេះប្រសិនបើសម្រេចតាមការស្នើសុំរបស់ចុងចម្លើយក្នុងការយកកូនទៅលេងរៀងរាល់ថ្ងៃសៅរ៍ អាទិត្យ នេះ គឺពិតជាប៉ះពាល់ដល់ក្មេងពិតប្រាកដមែន ។

**៣.២-ការកំណត់អំពីបំណុល ចំនួន ៤៥.០០០ USD (បួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ជាបំណុលរួម ឬបំណុលដោយឡែករបស់ចុងចម្លើយ (ប្រាក់ដែលបានទិញអចលនវត្ថុ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២៥០៣០៨១៣-០៤៨៧)៖**

**- ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ៖** ពាក់ព័ន្ធនឹងទ្រព្យក្នុងចំណងអាពាហ៍ពិពាហ៍របស់ដើមចោទ និងចុងចម្លើយ គឺភាគីទាំងសងខាងនៅមិនទាន់ឯកភាពគ្នានោះទេ ដោយដើមចោទបានអះអាងថា បំណុលចំនួន ៤៥.០០០ (បួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក គឺខ្លួនមិនដឹងអំពីដំណើរការនៃការកម្ចីប្រាក់នោះទេ ចំណែកឯចុងចម្លើយអះអាងថា ជាទ្រព្យរួមបំណុល ។ ហើយកូនក្តីរបស់ខ្លួនក៏មិនបានផ្តិតមេដៃលើកិច្ចសន្យាខ្ចីប្រាក់នោះដែរ ហេតុដូចនេះ កូនក្តី របស់ខ្លួនសុំបដិសេធចោលទាំងស្រុង ។

**- ការអះអាងរបស់ចុងចម្លើយ៖** ចំពោះបំណុល ចំនួន ៤៥,០០០ USD (បួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក គឺជាទ្រព្យរួមបំណុល ដែលខ្លួនបានខ្ចីពីបងប្រុសរបស់ខ្លួន ហើយមិនទាន់បានសងនោះទេ ហើយដើមចោទក៏បានដឹងលឺដែរ ពីព្រោះពេលដែលខ្លួនចង់ទិញដីនៅមេមត់ ហើយខ្លួនបានសួរគាត់ពីបញ្ហាលុយ ហើយដើមចោទបានប្រាប់ខ្លួនថា ខ្លួនមិនមានលុយទេ ដូចនេះខ្លួនក៏បានប្រាប់ទៅដើមចោទថា ខ្លួនខ្ចីលុយពីបងប្រុសទៅទិញដីហើយ



Scanned with CamScanner

ចាំរកសងគាត់ទៅ តែក្រោយមកដើមចោទបែរជាថាមិនដឹងទៅវិញ ។ ប្រសិនបើដើមចោទចង់បែងចែកដីនៅមេមត់ជាពីរចំណែកស្មើគ្នា លុះត្រាតែចូលរួមដោះបំណុលសងម្ចាស់បំណុលជាមុនសិន ។

**៣.៣-ការកំណត់អំពីទ្រព្យជាគ្រឿងអលង្ការ ជាទ្រព្យរួម ឬ ទ្រព្យដោយឡែករបស់ចុងចម្លើយ៖**

- **ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ៖** គ្រឿងអលង្ការដែលចុងចម្លើយបានលើកឡើង គឺអំណោយដែលចុងចម្លើយបានទិញឲ្យកូនក្តីខ្លួនក្នុងឱកាសថ្ងៃខួបកំណើត និងកម្មវិធីផ្សេងៗ ចំពោះពាក្យថា អំណោយ គឺកូនក្តីខ្លួនមិនមានកាតព្វកិច្ចនឹងសងត្រឡប់ទៅវិញនោះទេ ។

- **ការអះអាងរបស់ចុងចម្លើយ៖** ដោយសារតែពេលដែលខ្លួនទិញអំណោយជាគ្រឿងអលង្ការនោះ គឺដើមចោទជាប្រពន្ធ ប៉ុន្តែបើមិនមែនជាប្តីប្រពន្ធនឹងគ្នាទេ ខ្លួនសូមទាមទារយកវិញ ។

**៣.៤-ការកំណត់អំពីប្រាក់ ចំនួន ១៧.០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ជាទ្រព្យរួម ឬ ទ្រព្យដោយឡែករបស់ដើមចោទ៖**

- **ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ៖** ចំពោះប្រាក់ ចំនួន ១៧,០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ដែលចុងចម្លើយបានយកពីកូនក្តីខ្លួន ទៅទិញឡានដោយដាក់ឈ្មោះប្អូនរបស់ខ្លួន ចំណុចនេះចុងចម្លើយបានទទួលស្គាល់រួចហើយនៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (លើកទី២) ប៉ុន្តែចុងចម្លើយបានធ្វើការអះអាងថាជាទ្រព្យរួម ត្រង់ចំណុចនេះប្រាក់ ចំនួន ១៧.០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ដែលកូនក្តីខ្លួនបានផ្តល់ឲ្យចុងចម្លើយយកទៅទិញឡាន គឺជាប្រាក់ផ្ទាល់ខ្លួនរបស់កូនក្តីរបស់ខ្លួន គឺជាទ្រព្យដោយឡែក ។

-**ការអះអាងរបស់ចុងចម្លើយ៖** ប្រសិនបើដើមចោទលើកយកប្រាក់ ចំនួន ១៧.០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ដែលខ្លួនយកទៅទិញឡានដឹកឥវ៉ាន់រកស៊ី ទាល់តែដើមចោទព្រមយកគ្រឿងអលង្ការពេជ្រមានដូចជា ខ្សែករ កងដៃ ក្រវិល (តម្លៃចំនួនប្រាំបីពាន់ដុល្លារអាមេរិក) ដែលខ្លួនបានទិញឲ្យ មកគិតគូរថែមថយគ្នា និងយល់ព្រមផ្តិតមេដៃប្រគល់ដីដែលបានរៀបរាប់ខាងលើមកឲ្យខ្លួនផ្តាច់មុខ ក្នុងការយកមកដោះស្រាយសងម្ចាស់បំណុលក្នុងពេលតែមួយ។ ប្រសិនបើដើមចោទមិនព្រមតាមការស្នើសុំខាងលើទេ ខ្លួនចាត់ទុកថាប្រាក់ចំនួន ១៧.០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក និងគ្រឿងអលង្ការពេជ្រ មានដូចជា ខ្សែករ កងដៃ ក្រវិល (តម្លៃចំនួនប្រាំបីពាន់ដុល្លារអាមេរិក) គឺជាទ្រព្យរួម ពីព្រោះប្រាក់ និងគ្រឿងអលង្ការទាំងនោះ គឺខ្លួន និងដើមចោទមាន និងបានទិញក្នុងចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវស្របច្បាប់ ។

## III. <u>សំអាងហេតុ</u>

### ក/ ការវិនិច្ឆ័យអំពីមូលហេតុនៃការលែងលះ

#### ១-ការទទួលស្គាល់អង្គហេតុ

រឿងក្តីនេះ តាមរយៈនៃការអះអាងរបស់ភាគីដូចខាងលើ ឃើញថា ក្នុងពេលរួមរស់ជាមួយគ្នា ភាគីមានទំនាស់គ្នា ឈ្លោះប្រកែកគ្នាជាញឹកញាប់ និងបានបែកលំនៅសង្វាសពីគ្នារួចហើយ ពិតមែន ម៉្យាងវិញទៀតភាគីក៏ឯកភាពគ្នាក្នុងការលែងលះគ្នាផងដែរ ដូចនេះ តុលាការអាចទទួលស្គាល់ថា ពិតជាមានអង្គហេតុ និងមូលហេតុនៃការលែងលះគ្នាកើតឡើងចំពោះភាគីដូចការអះអាងរបស់ដើមចោទ ប្រាកដមែន។ យោងតាមមាត្រា ៩៧៨ កថាខណ្ឌទី ១ ចំណុច "ង" ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បានចែងថា ៖ ប្តី ឬ ប្រពន្ធ អាចដាក់ពាក្យបណ្តឹងលែងលះគ្នាបាន តែក្នុងករណីដែលកំណត់ខាងក្រោមនេះ ៖ ចំណុច "ង. ករណី ផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន" ។ ទាំងដើមចោទ និងចុងចម្លើយ បានបង្ហាញភាពអស់ចិត្ត អស់អារម្មណ៍ អស់មនោសញ្ចេតនានឹងរួមរស់ជាមួយចុងចម្លើយ និងមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍តទៅទៀត ។ តុលាការយល់ឃើញថា ទំនាក់ទំនងអាពាហ៍ពិពាហ៍នេះបានបែកបាក់



Scanned with CamScanner

ទៅហើយក៏គ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាននោះទេ ដោយសារភាគីអស់មនោសញ្ចេតនានឹងគ្នា ។ ដូច្នេះ បណ្តឹងទាមទារលែងលះរបស់ដើមចោទ គឺមានមូលហេតុ ។

**២-ការសន្និដ្ឋានៈ**

ស្ថានភាពគ្រួសាររបស់គូភាគីមានសភាពធ្ងន់ធ្ងរ និងត្រូវបានបែកបាក់ គ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានទេ ដោយសារភាគីអស់មនោសញ្ចេតនាពីគ្នា និងមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយគ្នាតទៅទៀត ហើយទោះបីតុលាការព្យាយាមសាកល្បងធ្វើការផ្សះផ្សាច្រើនលើកច្រើនសារ ក៏ពុំទទួលបានលទ្ធផលដែរ តុលាការអស់លទ្ធភាពក្នុងការផ្សះផ្សាតទៅទៀត ដូច្នេះ គប្បីតុលាការសម្រេចលែងលះ ដើមចោទ និងចុងចម្លើយ ។

**ខ/ ការវិនិច្ឆ័យចំពោះការកំណត់អំពីអ្នកមានអំណាចមេបា**

**១-ការទទួលស្គាល់អង្គហេតុ**

អង្គហេតុដែលតុលាការទទួលស្គាល់តាមរយៈភស្តុតាង ដូចបានកត់ត្រាមកដល់ចំណុចចុងក្រោយមានដូចតទៅៈ

១.១-ក្នុងអំឡុងអាពាហ៍ពិពាហ៍ ដើមចោទ និងចុងចម្លើយ បង្កើតបានកូនមួយនាក់ ឈ្មោះ [redacted] ដេវីត ភេទប្រុស កើតថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ (ភស្តុតាងមានៈ សំបុត្រកំណើតលេខៈ១៣៨ នៃសៀវភៅកំណើតលេខៈ ០៤/១៩ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩) ។

១.២-មុនពេលដែលដើមចោទដាក់ពាក្យបណ្តឹងសុំលែងលះ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ ភាគីបានបែកលំនៅសង្វាសពីគ្នារួចទៅហើយ ក្រោយពេលភាគីបានបែកបាក់គ្នានេះ គឺកូនស្ថិតនៅក្រោមការគ្រប់គ្រងចិញ្ចឹមបីបាច់របស់ដើមចោទ (ភស្តុតាងៈ ការអះអាងរបស់ភាគីក្នុងពេលត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់) ។

១.៣-នៅក្នុងពេលត្រៀមសម្រាប់ការទាញហេតុផល គឺភាគីដើមចោទបានទាមទារកំណត់ថា ខ្លួនជាអ្នកមានអំណាចមេបាលើកូន ចំណែកឯខាងចុងចម្លើយ ក៏បានឯកភាពគ្នាលើការស្នើសុំរបស់ដើមចោទក្នុងការសុំសិទ្ធិធ្វើជាអ្នកមានអំណាចមេបាលើកូនផងដែរ ។

**២-សេចក្តីសន្និដ្ឋានៈ**

តាមការពិភាក្សារបស់ភាគី គឺមានការឯកភាពគ្នាក្នុងការកំណត់ឲ្យដើមចោទជាអ្នកមានអំណាចមេបា ដូចនេះគប្បីតុលាការ កំណត់ឲ្យដើមចោទជាអ្នកមានអំណាចមេបាលើកូន ឈ្មោះ [redacted] ដេវីត ផ្អែកតាមកថាខណ្ឌទី១ មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី ។

**គ/ ការវិនិច្ឆ័យចំពោះការជួប និងការប្រាស្រ័យទាក់ទងកូន**

ក្រោយពេលលែងលះ ឪពុក ឬ ម្តាយដែលមិនមានអំណាចមេបាលើកូន មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន (កថាខណ្ឌទី១ មាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី) ។ ឪពុក ម្តាយដែលមានបំណងចង់លែងលះគ្នា ត្រូវពិភាក្សា និងកំណត់អំពីរបៀបចូលជួប (កថាខណ្ឌទី២ មាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី) ។ បើការពិភាក្សាគ្នាពុំបានសម្រេច ឬ ពុំអាចធ្វើការពិភាក្សាបានទេ តុលាការត្រូវកំណត់អំពីរបៀបចូលជួបប្រាស្រ័យតាមការទាមទាររបស់ឪពុក ម្តាយ (កថាខណ្ឌទី៤ មាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី) ។

តុលាការត្រូវកំណត់អំពីការចូលជួបប្រាស្រ័យទាក់ទង ដោយយក "ផលប្រយោជន៍របស់កូនជាអាទិភាព" (កថាខណ្ឌទី៦ មាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី) ។

**១-ការទទួលស្គាល់អង្គហេតុ**

១.១-កូនរបស់ដើមចោទ និងចុងចម្លើយ កន្លងមកដើមចោទក៏បានចូលរួមមើលថែរក្សាកូន បង្រៀន បំបៅទឹកដោះគោកូន ហើយពេលដែលកូនឈឺតាំងពីកើតមក រហូតដល់មានរឿងកើតឡើងក្នុងគ្រួសារ គឺតែងតែនៅ

ក្បែរកូនគ្រប់ពេល និងយកកូនទៅព្យាបាលនៅពេទ្យភ្នំពេញ ហើយនឹងបានចំណាយលើការព្យាបាលកូន សម្ភារៈប្រើប្រាស់របស់កូន ទឹកដោះគោកូនរាល់ខែ ។

១.២-កូនរបស់ដើមចោទ និងចុងចម្លើយ សង្ស័យថាកើតជម្ងឺអូទីស្សឹម (មិនសូវចេះនិយាយស្តី ឬ ប្រាស្រ័យទាក់ទងជាមួយគេ) ហេតុនេះ ប្រសិនបើសង្ស័យថាកូនមានជម្ងឺអូទីស្សឹម គឺត្រូវយកកូនមកលេងប្រាស្រ័យទាក់ទងជាមួយក្មេងដទៃទៀត ក៏ដូចជាយកកូនទៅសាលារៀន បង្ហាត់បង្រៀនកូន ពីរបៀបរស់នៅប្រចាំថ្ងៃ និងពិសេសជាងនេះទៅទៀត គឺត្រូវមានការចូលរួមមើលថែទាំពីឪពុកម្តាយជាចាំបាច់បំផុត ។

១.៣-ប្រសិនបើសម្រេចតាមការស្នើសុំរបស់ចុងចម្លើយ ដែលទាមទារយកកូនទៅលេងនៅថ្ងៃសៅរ៍ អាទិត្យជារៀងរាល់សប្តាហ៍ និងនៅពេលមានបុណ្យជាតិ អាចនាំឲ្យមានផលប៉ះពាល់ដល់កូន ដោយសារតែក្មេងទើបតែមានអាយុ ០៣ ឆ្នាំ ម៉្យាងវិញទៀត កូន កំពុងតែសិក្សា ចំណែកឯខាងក្រុមគ្រូពេទ្យជំនាញកំពុងតែពិនិត្យ ហើយសង្ស័យថាកូនរបស់កូនក្តីរបស់ខ្លួនអាចនឹងកើតជម្ងឺអូទីស្សឹម ដែលចាំបាច់ត្រូវមានការមើលថែទាំជាប្រចាំ និងដោយយកចិត្តទុកដាក់បំផុតពីម្តាយដែលជាកូនក្តីរបស់ខ្លួន ។

**២-សេចក្តីសន្និដ្ឋាន**

ផ្អែកតាមអង្គហេតុដែលបានទទួលស្គាល់ខាងលើ និងដោយយក "ផលប្រយោជន៍របស់កូនជាអាទិភាព" តុលាការទទួលស្គាល់ថា ចុងចម្លើយជាឪពុកដែលមិនមែនជាអ្នកមានអំណាចមេបាលើកូន មានសិទ្ធិក្នុងការទៅសួរសុខទុក្ខ និងជួបប្រាស្រ័យទាក់ទងកូនបានគ្រប់ពេលវេលាដែលសមស្រប និងតម្រូវឲ្យភាគីទទួលបានអំណាចមេបាបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាង ដល់ចុងចម្លើយដើម្បីបានសួរសុខទុក្ខ និងជួបប្រាស្រ័យទាក់ទងជាមួយកូន បានសមរម្យ ស្របតាមមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។

ចុងចម្លើយ ជាឪពុកដែលមានការទទួលខុសត្រូវចំពោះកូន ចេះស្រលាញ់កូន ចេះមើលថែកូន យកចិត្តទុកដាក់ចំពោះកូន និង ផ្តល់ភាពកក់ក្តៅដល់កូន ផងដែរ ។

ចុងចម្លើយ បានសុំសិទ្ធិក្នុងការយកកូនទៅលេងជារៀងរាល់ចុងសប្តាហ៍ ពោលគឺយកកូនទៅលេងនៅថ្ងៃសៅរ៍ ដោយយកមកសម្រាកមួយយប់ (គេងនៅផ្ទះចុងចម្លើយ) ហើយថ្ងៃអាទិត្យយកកូនទៅឲ្យដើមចោទវិញ និងសុំយកកូនទៅលេងក្នុងពេលមានកម្មវិធីបុណ្យទានប្រពៃណី និងបុណ្យទានដែលកើតឡើងជាយថាហេតុ ចូលរួមបានតាមជាក់ស្តែង ។ ដោយសារតែកូនរបស់ដើមចោទ និងចុងចម្លើយនៅតូច មានអាយុទើបតែ ០៣ ឆ្នាំ ហើយសព្វថ្ងៃនៅជាមួយដើមចោទជាម្តាយនៅភ្នំពេញ ឆ្ងាយពីផ្ទះចុងចម្លើយដែលនៅស្រុកមេមត់ខេត្តត្បូងឃ្មុំ ហេតុដូច្នេះ ការដែលអនុញ្ញាតឲ្យកូនតូចធ្វើដំណើរផ្លូវឆ្ងាយ និងញឹកញាប់ វានឹងអាចនឹងមានការប៉ះពាល់ដល់ក្មេងទាំងផ្នែកសុខភាព និងស្មារតី ម៉្យាងវិញទៀត កូនរបស់ដើមចោទ និងចុងចម្លើយ កំពុងតែសិក្សា និងមានការពិនិត្យតាមដានរបស់ពេទ្យ លើជម្ងឺអូទីស្សឹម ផងដែរ ។ ហេតុនេះ គប្បីតុលាការសម្រេចអនុញ្ញាតឲ្យចុងចម្លើយអាចយកកូនមកលេងបានក្នុងរយៈពេលមួយសមរម្យគឺ ពីរសប្តាហ៍ម្តង និងអាចឆ្លើយតបទៅនឹងភាពបត់បែនចំពោះស្ថានភាពរបស់កូន ហើយនៅពេលដែលចូលជួបប្រាស្រ័យទាក់ទងជាមួយកូនជាក់ស្តែង ដើមចោទដែលជាអ្នកមានអំណាចមេបាត្រូវសហការគ្នាជាមួយចុងចម្លើយ ដើម្បីអនុវត្តការប្រាស្រ័យទាក់ទងនេះឲ្យបានល្អប្រសើរ ។

**ឃ/ ការវិនិច្ឆ័យចំពោះការបែងចែកទ្រព្យសម្បត្តិ**

អំពីទ្រព្យសម្បត្តិដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែកទ្រព្យសម្បត្តិ ទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ វត្ថុតែជាគោលការណ៍នឹងត្រូវក្លាយជាទ្រព្យសម្បត្តិរួម (មាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណី) ហើយនៅក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយក ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម (ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី)។ ការណ៍ដែលលើកឡើងបែបនេះគឺដោយសារតែប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមក (មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណី) ហេតុនេះគឺអាចមានការយល់ឃើញថា ទ្រព្យសម្បត្តិដែលប្តីប្រពន្ធ ទទួលបាននៅក្នុងអំឡុង



Scanned with CamScanner

ពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបានតាមរយៈការសហការគ្នារវាងប្តីប្រពន្ធ ដូច្នេះ នៅពេលដែលប្តីប្រពន្ធលែងលះគ្នា ក៏គប្បីយកទ្រព្យសម្បត្តិនេះមកជម្រះបញ្ជីផងដែរ។ ជាពិសេសទ្រព្យសម្បត្តិរួមដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក គួរតែជាទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបាន គិតចាប់ពីពេលរៀបអាពាហ៍ពិពាហ៍រហូតដល់ពេលដែលរស់នៅបែកគ្នា។

រវាងដើមចោទ និងចុងចម្លើយមានទ្រព្យសម្បត្តិដូចជា៖ ផ្ទះវីឡាកូនកាត់ (បង់រំលស់) ផ្ទះលេខ ៣០ ផ្លូវP៤៦ គំរោងផាកលេន លេខ ៥៩៨ មានទីតាំងស្ថិតនៅសង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សកែវ រាជធានីភ្នំពេញ, បំណុលចំនួន ៤៥.០០០ USD (បួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក (ប្រាក់ដែលបានទិញអចលនវត្ថុ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៣០៨១៣-០៤៨៧), ទ្រព្យជាគ្រឿងអលង្ការ ៣ ឈុត មានតម្លៃប្រហាក់ប្រហែល ៨.០០០ (ប្រាំបីពាន់) ដុល្លាអាមេរិក និង ប្រាក់ចំនួន ១៧.០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ។

**១-ការទទួលស្គាល់អង្គហេតុ**

១.១-រវាងដើមចោទ និងចុងម្លើយ បានទទួលស្គាល់ និងព្រមព្រៀងថា ទ្រព្យសម្បត្តិរួមគឺ ផ្ទះវីឡាកូនកាត់ (បង់រំលស់) ផ្ទះលេខ ៣០ ផ្លូវP៤៦ គំរោងផាកលេន លេខ ៥៩៨ មានទីតាំងស្ថិតនៅសង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

១.២-ចំពោះ អចលនវត្ថុ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៣០៨១៣-០៤៨៧ ដែលទ្រព្យបំណុល ចំនួន ៤៥.០០០ USD (បួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក៖

- ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ៖ ពាក់ព័ន្ធនឹងទ្រព្យក្នុងចំណងអាពាហ៍ពិពាហ៍របស់ដើមចោទ និងចុងចម្លើយ គឺភាគីទាំងសងខាងនៅមិនទាន់ឯកភាពគ្នានោះទេ ដោយដើមចោទបានអះអាងថា បំណុល ចំនួន ៤៥.០០០ (បួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក គឺខ្លួនមិនដឹងអំពីដំណើរការនៃការកម្ចីប្រាក់នោះទេ ចំណែកឯចុងចម្លើយអះអាងថា ជាទ្រព្យរួមបំណុល ។ ហើយកូនក្តីរបស់ខ្លួនក៏មិនបានផ្តិតមេដៃលើកិច្ចសន្យាខ្ចីប្រាក់នោះដែរ ហេតុដូចនេះ កូនក្តី របស់ខ្លួនសុំបដិសេធចោលទាំងស្រុង ។

- ការអះអាងរបស់ចុងចម្លើយ៖ ចំពោះបំណុល ចំនួន ៤៥,០០០ USD (បួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក គឺជាទ្រព្យរួមបំណុល ដែលខ្លួនបានខ្ចីពីបងប្រុសរបស់ខ្លួន ហើយមិនទាន់បានសងនោះទេ ហើយដើមចោទក៏បានដឹងលឺដែរ ពីព្រោះពេលដែលខ្លួនចង់ទិញដីនៅមេមត់ ហើយខ្លួនបានសួរគាត់ពីបញ្ហាលុយ ហើយដើមចោទបានប្រាប់ខ្លួនថា ខ្លួនមិនមានលុយទេ ដូចនេះខ្លួនក៏បានប្រាប់ទៅដើមចោទថា ខ្លួនខ្ចីលុយពីបងប្រុសទៅទិញដីហើយចាំរកសងគាត់ទៅ តែក្រោយមកដើមចោទបែរជាថាមិនដឹងទៅវិញ ។ ប្រសិនបើដើមចោទចង់បែងចែកដីនៅមេមត់ជាពីរចំណែកស្មើគ្នា លុះត្រាតែចូលរួមដោះបំណុលសងម្ចាស់បំណុលជាមុនសិន ។

១.៣-ចំពោះ ទ្រព្យជាគ្រឿងអលង្ការ ៣ ឈុត មានតម្លៃ ៨.០០០ (ប្រាំបីពាន់) ដុល្លាអាមេរិក៖

- ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ៖ គ្រឿងអលង្ការដែលចុងចម្លើយបានលើកឡើង គឺអំណោយដែលចុងចម្លើយបានទិញឲ្យកូនក្តីខ្លួនក្នុងឱកាសថ្ងៃខួបកំណើត និងកម្មវិធីផ្សេងៗ ចំពោះពាក្យថា អំណោយ គឺកូនក្តីខ្លួនមិនមានកាតព្វកិច្ចនឹងសងត្រឡប់ទៅវិញនោះទេ ។

- ការអះអាងរបស់ចុងចម្លើយ៖ ដោយសារតែពេលដែលខ្លួនទិញអំណោយជាគ្រឿងអលង្ការនោះ គឺដើមចោទជាប្រពន្ធ ប៉ុន្តែបើមិនមែនជាប្តីប្រពន្ធនឹងគ្នាទេ ខ្លួនសូមទាមទារយកវិញ ហើយព្រទ្យនេះជាទ្រព្យរួមព្រោះខ្លួនទិញក្នុងអំឡុងចំណងអាពាហ៍ពិពាហ៍ ។

១.៤-ចំពោះ ប្រាក់ចំនួន ១៧.០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក៖

- ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ៖ ចំពោះប្រាក់ ចំនួន ១៧,០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ដែលចុងចម្លើយបានយកពីកូនក្តីខ្លួន ទៅទិញឡានដោយដាក់ឈ្មោះប្អូនរបស់ខ្លួន ចំណុចនេះចុងចម្លើយបានទទួលស្គាល់រួចហើយនៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (លើកទី២) ប៉ុន្តែចុងចម្លើយ

បានធ្វើការអះអាងថាជាទ្រព្យរួម ត្រង់ចំណុចនេះប្រាក់ ចំនួន ១៧.០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ដែលកូនក្តីខ្លួនបានផ្តល់ឲ្យចុងចម្លើយយកទៅទិញឡាន គឺជាប្រាក់ផ្ទាល់ខ្លួនរបស់កូនក្តីរបស់ខ្លួន គឺជាទ្រព្យដោយឡែក ។

- ការអះអាងរបស់ចុងចម្លើយ៖ ប្រសិនបើដើមចោទលើកយកប្រាក់ ចំនួន ១៧.០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ដែលខ្លួនយកទៅទិញឡានដឹកឥវ៉ាន់រកស៊ី ទាល់តែដើមចោទព្រមយកគ្រឿងអលង្ការពេជ្រ មានដូចជា ខ្សែករ កងដៃ ក្រវិល (តម្លៃចំនួនប្រាំបីពាន់ដុល្លារអាមេរិក) ដែលខ្លួនបានទិញឲ្យ មកគិតគូរថែមថយគ្នា និងយល់ព្រមផ្តិតមេដៃប្រគល់ដីដែលបានរៀបរាប់ខាងលើមកឲ្យខ្លួនផ្តាច់មុខ ក្នុងការយកមកដោះស្រាយសងម្ចាស់បំណុលក្នុងពេលតែមួយ។ ប្រសិនបើដើមចោទមិនព្រមតាមការស្នើសុំខាងលើទេ ខ្លួនចាត់ទុកថាប្រាក់ចំនួន ១៧.០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក និងគ្រឿងអលង្ការពេជ្រ មានដូចជា ខ្សែករ កងដៃ ក្រវិល (តម្លៃចំនួនប្រាំបីពាន់ដុល្លារអាមេរិក) គឺជាទ្រព្យរួម ពីព្រោះប្រាក់ និងគ្រឿងអលង្ការទាំងនោះ គឺខ្លួន និងដើមចោទមាន និងបានទិញក្នុងចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវស្របច្បាប់ ។

**២-ការវិនិច្ឆ័យ**

-ចំពោះ អចលនវត្ថុ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៣០៨១៣-០៤៨៧ ដែលទ្រព្យបំណុល ចំនួន ៤៥.០០០ USD (បួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដើមចោទអះអាងថា ខ្លួនមិនបានដឹង និងទទួលស្គាល់ពីការខ្ចីលុយចំនួនខាងលើនេះយកទៅទិញដីទេ ព្រោះចុងចម្លើយជាអ្នកផ្តិតមេដៃខ្ចីតែម្នាក់ឯង ។ ទោះបីជាយ៉ាងនេះក៏ដោយ តុលាការយល់ឃើញថា អចលនវត្ថុ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៣០៨១៣-០៤៨៧ គឺមានឈ្មោះដើមចោទ និងចុងចម្លើយជាម្ចាស់កម្មសិទ្ធិ ការដែលមានឈ្មោះដើមចោទក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនេះ ដើមចោទក៏មិនបានបង្ហាញពីប្រភពនៃប្រាក់សម្រាប់ទិញ ឬ ប្រភពនៃទ្រព្យនេះបានទេ មានតែចុងចម្លើយទេដែលបានបង្ហាញថា អចលនវត្ថុនេះគឺបានមកពីការខ្ចីប្រាក់ ចំនួន ៤៥.០០០ USD (បួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ពីបងប្រុស ។ ដូចនេះ អចលនវត្ថុ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៣០៨១៣-០៤៨៧ គឺជាទ្រព្យសម្បត្តិរួម ដែលបានមកពីការខ្ចីប្រាក់របស់ដើមចោទ និងចុងចម្លើយ នាំឲ្យវាក្លាយជាកម្មវត្ថុនៃការបែងចែក ។

-ចំពោះ ទ្រព្យជាគ្រឿងអលង្ការ ៣ ឈុត មានតម្លៃ ៨.០០០ (ប្រាំបីពាន់) ដុល្លាអាមេរិក ដើមចោទអះអាងថាចុងចម្លើយបានឲ្យខ្លួនហើយ មិនអាចយកវិញបានទេ ។ តុលាការយល់ឃើញថា ទ្រព្យជាគ្រឿងអលង្ការនេះ ជាទ្រព្យដែលកើតមានក្នុងអំឡុងចំណងអាពាហ៍ពិពាហ៍ ដែលចុងចម្លើយបានយកប្រាក់ដែលជាទ្រព្យរួមទៅទិញជាកាដូឲ្យប្រពន្ធ ដូច្នេះវានៅតែរក្សាធាតុដើមរបស់វាដ៏ដែល គឺជាទ្រព្យសម្បត្តិរួមរបស់ដើមចោទ និងចុងចម្លើយ នាំឲ្យវាក្លាយជាកម្មវត្ថុនៃការបែងចែក ។

-ចំពោះ ប្រាក់ចំនួន ១៧.០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ដើមចោទបានអះអាងថា ជាទ្រព្យដោយឡែករបស់ខ្លួន ចុងចម្លើយបានយកប្រាក់នេះពីខ្លួនដើម្បីទិញឡាន ។ ការដែលដើមចោទបានអះអាងថាប្រាក់ចំនួន ១៧.០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ជាទ្រព្យដោយឡែករបស់ខ្លួន ដើមចោទដែលមានបន្ទុកក្នុងការបង្ហាញភស្តុតាង មិនបានបង្ហាញភស្តុតាងដែលអាចបញ្ជាក់ពីប្រភេទនៃទ្រព្យនេះបានទេ គឺមានត្រឹមតែជាការអះអាងប៉ុណ្ណោះ ។ តុលាការយល់ឃើញថា ទ្រព្យនេះ ជាទ្រព្យដែលកើតមានក្នុងអំឡុងចំណងអាពាហ៍ពិពាហ៍ ដែលចុងចម្លើយបានយកប្រាក់នេះពីដើមចោទទៅទិញឡានដើម្បីប្រើប្រាស់ជាប្រយោជន៍រួមក្នុងគ្រួសារ ដូច្នេះ គឺជាទ្រព្យសម្បត្តិរួមរបស់ដើមចោទ និងចុងចម្លើយ នាំឲ្យវាក្លាយជាកម្មវត្ថុនៃការបែងចែក ។

**៣-សេចក្តីសន្និដ្ឋាន**

ដូចបានរៀបរាប់ខាងលើនេះ ចំពោះ អចលនវត្ថុ (ផ្ទះវីឡាកូនកាត់) (បង់រំលស់) ផ្ទះលេខ ៣០ ផ្លូវP៤៦ គំរោងជាកលេន លេខ ៥៩៨ មានទីតាំងស្ថិតនៅសង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ, អចលនវត្ថុ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៣០៨១៣-០៤៨៧ ដែលទ្រព្យបំណុល ចំនួន ៤៥.០០០

USD (បួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក, ទ្រព្យជាគ្រឿងអលង្ការ ៣ ឈុត មានតម្លៃ ៨.០០០ (ប្រាំបីពាន់) ដុល្លាអាមេរិក និង ប្រាក់ចំនួន ១៧.០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក គឺជាទ្រព្យសម្បត្តិរួម ដូចនេះដើមចោទ និងចម្លើយក្នុងម្នាក់ៗមានចំណែក១ភាគ២ ទើបជាការសមរម្យ ។

**ខ/ អំពីបន្ទុកប្រាក់ប្រដាប់ក្តី៖**

បន្ទុកនៃប្រាក់ប្រដាប់ក្តី តុលាការទទួលស្គាល់អំពីការទាមទាររបស់ដើមចោទ (បណ្តឹងទាមទារលែងលះគ្នា) ដូច្នេះ មានន័យថាតុលាការបានទទួលស្គាល់អំពីមូលហេតុនៃការលែងលះ ដូចដើមចោទបានអះអាងនោះទេ។ ហេតុនេះ ចំពោះបន្ទុកនៃប្រាក់ប្រដាប់ក្តី ក៏គប្បីឲ្យ ភាគីចុងចម្លើយទទួលបន្ទុក (កថាខណ្ឌទី២ មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ចំពោះភាគនៃបន្ទុកដែលត្រូវទទួលនោះ បើពិចារណាទៅលើសំអាងហេតុដែលតុលាការបានទទួលស្គាល់នូវការទាមទាររបស់ដើមចោទ ដោយចុងចម្លើយមានអ្នកមានកំហុស ហើយដើមចោទត្រូវឈ្នះក្តីអំពីការលែងលះ ដូចនេះ គប្បី សម្រេចឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

**១- <u>លែងលះ</u>**

ដើមចោទឈ្មោះ [redacted] ដាវីន និងចុងចម្លើយឈ្មោះ [redacted] សុខណោង ។

**២- <u>កំណត់ថា</u>**

ដើមចោទឈ្មោះ [redacted] ដាវីន (ម្តាយ) ជាអ្នកមានអំណាចមេបាលើកូនប្រុសរវាងដើមចោទ និងចុងចម្លើយ ដែលមានឈ្មោះ [redacted] ដេវីត ភេទប្រុស កើតថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ ដែលមាន សំបុត្រកំណើតលេខ ១៣៨ នៃសៀវភៅកំណើតលេខៈ០៤/១៩ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ។

**៣- <u>របៀបចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន</u>**

-ទុកសិទ្ធិឲ្យចុងចម្លើយ ឈ្មោះ [redacted] សុខណោង ដែលគ្មានអំណាចមេបាលើកូន មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនដូចខាងក្រោម៖

៣.១- ដើមចោទត្រូវតែអនុញ្ញាត និងប្រគល់កូន ឈ្មោះ [redacted] ដេវីត ឲ្យទៅចុងចម្លើយ យកទៅលេង និងស្នាក់នៅផ្ទះរបស់ចុងចម្លើយ រៀងរាល់ ០២ (ពីរ) សប្តាហ៍ម្តង នៅថ្ងៃសៅរ៍ ហើយថ្ងៃអាទិត្យ ចុងចម្លើយត្រូវប្រគល់កូន ឲ្យទៅដើមចោទវិញ ។

៣.២- ដើមចោទត្រូវតែអនុញ្ញាត និងប្រគល់កូន ឈ្មោះ [redacted] ដេវីត ឲ្យទៅចុងចម្លើយ យកទៅលេង និងស្នាក់នៅផ្ទះរបស់ចុងចម្លើយ បន្ថែមទៀតបានករណីមានបុណ្យទាន ឬ កម្មវិធីផ្សេងៗដែលចាំបាច់ជាក់ស្តែង ដោយឲ្យឆ្លើយតបទៅនឹងភាពបត់បែនចំពោះស្ថានភាពរបស់កូន ។

៣.៣- ចុងចម្លើយ មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន តាមស្ថានភាពចាក់ស្តែងរបស់កូន និងមានសិទ្ធិឧបត្ថម្ភ ផ្គត់ផ្គង់គ្រប់បែបយ៉ាងបន្ថែម ដល់កូនតាមលទ្ធភាព ហើយដើមចោទត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ចុងចម្លើយ ក្នុងការអនុវត្តសិទ្ធិនេះ ។

**៤- <u>បែងចែកទ្រព្យសម្បត្តិនីមួយៗរបស់ដើមចោទ និងចុងចម្លើយដូចខាងក្រោម៖</u>**

៤.១- អចលនវត្ថុ ផ្ទះវីឡាកូនកាត់ (បង់រំលស់) ផ្ទះលេខ ៣០ ផ្លូវP៤៦ គំរោងផាកលេន លេខ ៥៩៨ មានទីតាំងស្ថិតនៅសង្កាត់ច្រាំងចំរេះ២ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និងចុងចម្លើយ ត្រូវបែងចែកក្នុងចំណែកម្នាក់ៗ ១ភាគ២ ។

៤.២- អចលនវត្ថុ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៣០៨១៣-០៤៨៧) ស្ថិតនៅភូមិសង្គមមានជ័យចាស់ ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និងចុងចម្លើយ ត្រូវបែងចែកក្នុងចំណែកម្នាក់ៗ ១ភាគ២ ។



Scanned with CamScanner

៤.៣- ទ្រព្យជាគ្រឿងអលង្ការ ៣ (បី) ឈុត គឺជាទ្រព្យសម្បត្តិរួមរបស់ដើមចោទ និងចុងចម្លើយ ត្រូវបែងចែកជា ២ (ពីរ) ចំណែកស្មើគ្នា ។

៤.៤- ប្រាក់ចំនួន ១៧.០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក គឺជាទ្រព្យសម្បត្តិរួមរបស់ដើមចោទ និងចុងចម្លើយ ត្រូវបែងចែកជា ២ (ពីរ) ចំណែកស្មើគ្នា ។

៥- **ការទាមទារលើសពីនេះរបស់ភាគី៖** សម្រេចច្រានចោល ។

៦- **ប្រាក់ប្រដាប់ក្ដី** ជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះ ត្រូវបានប្រកាសជាសាធារណៈ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ ។ ក្នុងករណី មានបណ្ដឹងឧទ្ធរណ៍ត្រូវធ្វើឡើងនៅក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលលិខិតបញ្ជូនសាលក្រមនេះ ។

ថ្ងៃពុធ ៤រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ខេត្តត្បូងឃ្មុំ, ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២
**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និងត្រា** [redacted]

---

**សាលក្រមនេះបានថតចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃពុធ ៤រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ខេត្តត្បូងឃ្មុំ, ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២
**ក្រឡាបញ្ជី**
[redacted]

**បានឃើញ**
**ចៅក្រម**
[redacted]



Scanned with CamScanner